## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងរាជធានីភ្នំពេញ

សាលក្រមរដ្ឋប្បវេណី
លេខ: ១៤២ "ង"
ចុះថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ២០២០
សំណុំរឿងរដ្ឋប្បវេណីលេខ: ១៨១៤
ចុះថ្ងៃទី០៩ ខែ តុលា ឆ្នាំ២០១៩

បានបើកការទាញហេតុផលផ្ទាល់មាត់នាថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០២០ វេលាម៉ោង ០៩ និង០០ នាទីព្រឹក លើសំណុំរឿងរដ្ឋប្បវេណីលេខ ១៨១៤ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៩ សមាសភាពចូលរួមមាន៖

### ចៅក្រមជំនុំជម្រះ

លោកស្រី [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

### ក្រឡាបញ្ជី

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

**ដើមចោទ:** ឈ្មោះ [redacted] គីមមួយ ភេទស្រី អាយុ ៣៧ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នផ្ទះ [redacted]។

**អ្នកតំណាងដោយអាណត្តិ:** មេធាវី [redacted] ជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

**ចុងចម្លើយ:** ឈ្មោះ [redacted] សុផល្លា ភេទស្រី អាយុ ៣៨ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅសព្វថ្ងៃផ្ទះលេខ [redacted]។

### I. អង្គហេតុនិងចំណុចវិវាទ

១.ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ៖

១.១.បង្គាប់ឱ្យចុងចម្លើយ សងប្រាក់ ចំនួន USD ១៦០,០០០ (ដប់ប្រាំមួយម៉ឺនដុល្លារអាមេរិក)។

១.២.បង្គាប់ឱ្យចុងចម្លើយសងជំងឺចិត្ត និងការខាតបង់ពេលវេលា ចំនួន ៥០,០០០$(ប្រាំម៉ឺនដុល្លារអាមេរិក) ។

១.៣.បង្គាប់ឱ្យចុងចម្លើយ បង់ការប្រាក់តាមផ្លូវច្បាប់។

១.៤.សុំឱ្យប្រកាសថា សាលក្រមនេះមានអានុភាពអនុវត្តបណ្តោះអាសន្ន។

១.៥.សុំឱ្យចុងចម្លើយរ៉ាប់រងប្រាក់ប្រដាប់ក្តី និងការបង់ពន្ធផ្សេងៗដែលច្បាប់តម្រូវ។

២. ការពន្យល់ត្រួសៗអំពីរឿងក្តី

ចុងចម្លើយឈ្មោះ [redacted] សុផល្លា បានខ្ចីប្រាក់ពីដើមចោទឈ្មោះ [redacted] គីមមួយ ចំនួន USD១៦០,០០០ (ដប់ប្រាំមួយម៉ឺនដុល្លារអាមេរិក) ដូចមានក្នុងកិច្ចសន្យា នៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៩ និងបានកំណត់សងនៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៩ ក្នុងការខ្ចីប្រាក់នេះ ចុងចម្លើយបានចេញមូលប្បទានបត្រ័០១សន្លឹកលេខ ២០៤៤៨៧ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៩ របស់ធនាគារ [redacted] ដើម្បីឱ្យដើមចោទ ទៅបើកយកប្រាក់។ ដល់ថ្ងៃកំណត់ត្រូវបើកប្រាក់ ដើមចោទបានយកមូលប្បទានបត្រ ទៅបើកប្រាក់ តែត្រូវខាងធនាគារបញ្ជាក់ថា មូលប្បទានបត្រមិនមានសាច់ប្រាក់ ដើមចោទបានព្យាយាមឱ្យចុងចម្លើយយកប្រាក់មកទូទាត់ ប៉ុន្តែចុងចម្លើយចេះតែគេចវេស រហូតមកដល់បច្ចុប្បន្ននេះ ។

៣.អង្គហេតុដែលអះអាងដោយដើមចោទ

ដើមចោទឈ្មោះ [redacted] គីមមួយ បានអះអាងថា: នាងខ្ញុំ សុំរក្សាការទាមទារដូចក្នុងពាក្យបណ្តឹងចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១៩ ពោលគឺប្តឹងទាមទារឱ្យតុលាការចេញសាលក្រម បង្គាប់ឱ្យចុងចម្លើយសងប្រាក់ ចំនួន USD ១៦០,០០០

(ដប់ប្រាំមួយម៉ឺនដុល្លារអាមេរិក), បង្គាប់ឱ្យចុងចម្លើយសងជំងឺចិត្ត និងការខាតបង់ពេលវេលា ចំនួន ៥០,០០០$ (ប្រាំម៉ឺនដុល្លារអាមេរិក), បង្គាប់ឱ្យចុងចម្លើយ បង់ការប្រាក់តាមផ្លូវច្បាប់, សុំឱ្យប្រកាសថា សាលក្រមនេះមានអានុភាពអនុវត្តបណ្ដោះអាសន្ន និងសុំឱ្យចុងចម្លើយរ៉ាប់រងប្រាក់ប្រដាប់ក្ដី និងការបង់ពន្ធផ្សេងៗដែលច្បាប់តម្រូវ។

ចំពោះអង្គហេតុ និងមូលហេតុបញ្ជាក់ការទាមទារ គឺចុងចម្លើយឈ្មោះ [redacted] សុផល្លា បានខ្ចីប្រាក់ពីដើមចោទឈ្មោះ [redacted] គឹមមួយ ចំនួន USD១៦០,០០០(ដប់ប្រាំមួយម៉ឺនដុល្លារអាមេរិក) ដូចមានក្នុងកិច្ចសន្យា នៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៩ និងបានកំណត់សងនៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៩ ក្នុងការខ្ចីប្រាក់នេះ ចុងចម្លើយបានចេញមូលប្បទានបត្រ ០១សន្លឹក លេខ ២០៤៤៨៧ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៩ របស់ធនាគារ[redacted] ដើម្បីឱ្យដើមចោទទៅបើកយកប្រាក់។ ដល់ថ្ងៃកំណត់ត្រូវបើកប្រាក់ដើមចោទបានយកមូលប្បទានបត្រទៅបើកប្រាក់ តែត្រូវខាងធនាគារបញ្ជាក់ថា មូលប្បទានបត្រមិនមានសាច់ប្រាក់ ដើមចោទបានព្យាយាមឱ្យចុងចម្លើយយកប្រាក់មកទូទាត់ ប៉ុន្តែចុងចម្លើយចេះតែគេចវេស រហូតមកដល់បច្ចុប្បន្ននេះ។

៤.អង្គហេតុដែលអះអាងដោយចុងចម្លើយ

-ចុងចម្លើយឈ្មោះ [redacted] ផល្លា បានអះអាងថា: អវត្តមាន។

៥.ចំនុចគ្មានវិវាទ ៖ (គ្មាន)

៥.១.សារភាពតាមសេចក្ដីថ្លែងការណ៍របស់ដើមចោទ ទាក់ទងនឹងអង្គហេតុ។

៦.ចំនុចវិវាទ ៖ (គ្មាន)

## II. ការពិនិត្យភស្តុតាង

១.ភស្តុតាងជាឯកសាររបស់ដើមចោទ

១.១.កិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៩។

១.២.លិខិតប្រគល់-ទទួលមូលប្បទានបត្រ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៩។

១.៣.មូលប្បទានប័ត្រ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៩។

១.៤.លិខិតប្រគល់-ទទួលប្រាក់ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៩។

២.ភស្តុតាងជាឯកសាររបស់ចុងចម្លើយ ៖(គ្មាន)

៣.ការសាកសួរសាក្សី ៖ (គ្មាន)

## សំអាងហេតុ

ផ្អែកតាមលទ្ធផលនៃការទាញហេតុផលដោយផ្ទាល់មាត់ និងការពិនិត្យភស្តុតាងតុលាការយល់ឃើញថា:

០១).ដើមចោទឈ្មោះ [redacted] គឹមមួយ បានអះអាងថា: នាងខ្ញុំ សុំរក្សាការទាមទារដូចក្នុងពាក្យបណ្ដឹងចុះថ្ងៃទី ០៦ ខែតុលា ឆ្នាំ២០១៩ ពោលគឺ ប្ដឹងទាមទារឱ្យតុលាការចេញសាលក្រម បង្គាប់ឱ្យចុងចម្លើយ សងប្រាក់ ចំនួន USD ១៦០,០០០ (ដប់ប្រាំមួយម៉ឺនដុល្លារអាមេរិក), បង្គាប់ឱ្យចុងចម្លើយសងជំងឺចិត្ត និងការខាតបង់ពេលវេលា ចំនួន ៥០,០០០$(ប្រាំម៉ឺនដុល្លារអាមេរិក), បង្គាប់ឱ្យចុងចម្លើយបង់ការប្រាក់តាមផ្លូវច្បាប់, សុំឱ្យប្រកាសថា សាលក្រមនេះមានអានុភាពអនុវត្តបណ្ដោះអាសន្ន និងសុំឱ្យចុងចម្លើយរ៉ាប់រងប្រាក់ប្រដាប់ក្ដី និងការបង់ពន្ធផ្សេងៗដែលច្បាប់តម្រូវ។

ចំពោះអង្គហេតុ និងមូលហេតុបញ្ជាក់ការទាមទារ គឺចុងចម្លើយឈ្មោះ [redacted] សុផល្លា បានខ្ចីប្រាក់ពីដើមចោទឈ្មោះ [redacted] គឹមមួយ ចំនួន USD១៦០,០០០(ដប់ប្រាំមួយម៉ឺនដុល្លារអាមេរិក) ដូចមានក្នុងកិច្ចសន្យា នៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៩ និងបានកំណត់សងនៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៩ ក្នុងការខ្ចីប្រាក់នេះ ចុងចម្លើយបានចេញមូលប្បទានបត្រ០១សន្លឹកលេខ ២០៤៤៨៧ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៩ របស់ធនាគារ[redacted] ដើម្បីឱ្យដើមចោទទៅបើកយកប្រាក់។ ដល់ថ្ងៃកំណត់ត្រូវបើកប្រាក់ ដើមចោទបានយកមូលប្បទានបត្រទៅបើកប្រាក់ តែត្រូវខាងធនាគារបញ្ជាក់ថា មូល



Scanned with CamScanner

ប្បទានបត្រមិនមានសាច់ប្រាក់ដើមចោទ បានព្យាយាមឱ្យចុងចម្លើយយកប្រាក់មកខ្ទរទាត់ ប៉ុន្តែចុងចម្លើយចេះតែគេចវេស រហូតមកដល់បច្ចុប្បន្ននេះ ។

០២). ដើម្បីបញ្ជាក់ការអះអាងខាងលើ ដើមចោទ បានបង្ហាញភស្តុតាងជាឯកសាររួមមាន៖

២.១.កិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៩។

២.២.លិខិតប្រគល់-ទទួលមូលប្បទានបត្រ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៩។

២.៣.មូលប្បទានបត្រ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៩។

២.៤.លិខិតប្រគល់-ទទួលប្រាក់ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៩។

០៣). យោងតាមការអះអាងរបស់ដើមចោទ និងភស្តុតាងជាឯកសារអាចបញ្ជាក់ឱ្យឃើញថា ៖ ភាគីដើមចោទឈ្មោះ [redacted] គីមមួយ និងភាគីចុងចម្លើយឈ្មោះ [redacted] សុផល្លា ពិតជាមានទំនាក់ទំនងសិទ្ធិលើបំណុលជាមួយគ្នា ដែលអាចអោយតុលាការ ពិចារណា និងសម្រេច តាមច្បាប់។

០៤).ក្នុងនីតិវិធីកន្លងមក តុលាការបានធ្វើការកោះហៅ ភាគីចុងចម្លើយឈ្មោះ [redacted] សុផល្លា តាមការបញ្ជូនដីកាកោះតាមការផ្សាយជាសាធារណៈ និងនីតិវិធីផ្សេងៗ តាមផ្លូវច្បាប់រួចរាល់ហើយ ប៉ុន្តែភាគីចុងចម្លើយពុំបានចូលរួមនីតិវិធីតាមការកោះហៅរបស់តុលាការដោយគ្មានមូលហេតុ ដូច្នេះយោងតាមបញ្ញត្តិមាត្រា២០១ នៃក្រមនីតិវិធីរដ្ឋប្បវេណី បានកំណត់ថា បើចុងចម្លើយ មិនបានចូលបង្ហាញខ្លួនតាមកាលបរិច្ឆេទរបស់តុលាការ ត្រូវចាត់ទុកថា ចុងចម្លើយបានសារភាពតាមសេចក្តីថ្លែងការណ៍របស់ដើមចោទ ទាក់ទងនឹងអង្គហេតុ ហើយតុលាការអាចចេញសាលក្រមកំបាំងមុខចុងចម្លើយបាន។

០៥). ផ្អែកតាមកិច្ចសន្យាខ្ចីចងការប្រាក់ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៩, លិខិតប្រគល់-ទទួលប្រាក់ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៩ បង្ហាញអោយឃើញថា ទំហំសិទ្ធិលើបំណុលដែលភាគីទាំងពីរបានបង្កើត ពិតជាមានចំនួន ១៦០.០០០$ (ដប់ប្រាំមួយម៉ឺនដុល្លារអាមេរិក) ពិតប្រាកដមែន។

០៦). ដើមចោទឈ្មោះ [redacted] គីមមួយ បានទាមទារឱ្យចុងចម្លើយបង់អាត្រាការប្រាក់ តាមផ្លូវច្បាប់លើប្រាក់ដើមដែលជំពាក់ចំនួន ១៦០.០០០$ (ដប់ប្រាំមួយម៉ឺនដុល្លារអាមេរិក) គិតចាប់ពីថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៩ រហូតដល់ថ្ងៃអនុវត្តកាតព្វកិច្ច ចប់ដែលអាត្រាការប្រាក់តាមច្បាប់កំណត់នេះ ផ្អែកតាមបញ្ញត្តិមាត្រា៣៨៤ នៃក្រមរដ្ឋប្បវេណី ច្បាប់បានកំណត់ចំនួន ៥% ក្នុងមួយឆ្នាំ ផ្ទុយទៅវិញ យោងតាមកិច្ចសន្យាខ្ចីប្រាក់រវាងដើមចោទ និងចុងចម្លើយបានកំណត់អំឡុងពេលនៃការអនុវត្តកាតព្វកិច្ច ត្រឡប់ត្រឹមតែ០៧ថ្ងៃប៉ុណ្ណោះ ដូច្នេះការទាមទារឱ្យភាគីកូនបំណុលបង់អាត្រាការប្រាក់តាមច្បាប់កំណត់ គឺមិនអាចធ្វើការគណនាបានឡើយ ។

០៧). ដើមចោទបានទាមទារឲ្យតុលាការបង្គាប់ឲ្យចុងចម្លើយសង សំណងការខូចខាត និងសំណងជំងឺចិត្តចំនួន ៥០,០០០$ (ប្រាំម៉ឺនដុល្លារអាមេរិក) ប៉ុន្តែដើមចោទ មិនបានបង្ហាញភស្តុតាងណាមួយបញ្ជាក់ពីទំហំនៃការខូចខាត ដើម្បីធ្វើការទាមទារសំណងការខូចខាតឡើយ គប្បីតុលាការពិចារណា និងសម្រេចតាមទំហំនៃការខូចខាតជាក់ស្តែង។

០៨). ដើមចោទ បានស្នើសុំឱ្យតុលាការសម្រេចអនុញ្ញាតិការអនុវត្តន៍ជាបណ្តោះអាសន្ន គ្រង់ចំណុចសេចក្តីសម្រេចទាំងអស់តាមបញ្ញត្តិមាត្រា ១៩៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ដែលការទាមទារនេះ ឃើញថា ការទាមទារត្រង់ចំណុចទឹកប្រាក់ ចំនួន USD ១៦០.០០០$ (ដប់ប្រាំមួយម៉ឺនដុល្លារអាមេរិក) គឺមានភស្តុតាងច្បាស់លាស់ គប្បីតុលាការពិចារណា និងសម្រេចលើភាពចាំបាច់ក្នុងការស្នើសុំខាងលើ ។

០៩). ដោយសារការទាមទារ របស់ដើមចោទ មានមូលហេតុត្រឹមត្រូវ គប្បីតុលាការពិចារណា និងសម្រេចតាមការទាមទារខាងលើ រីឯប្រាក់ប្រដាប់ក្តីត្រូវអនុលោមតាមបញ្ញត្តិមាត្រា៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

## <u>សេចក្តីសម្រេច</u>

១.បង្គាប់ឱ្យចុងចម្លើយឈ្មោះ [redacted] សុផល្លា សងប្រាក់ ចំនួន USD ១៦០,០០០ (ដប់ប្រាំមួយម៉ឺនដុល្លារអាមេរិក) ទៅឱ្យដើមចោទឈ្មោះ [redacted] គីមមួយ។

២.ច្រានចោលការទាមទារ ត្រង់ចំណុចទាមទារឱ្យចុងចម្លើយឈ្មោះ [redacted] សុផល្លា បង់ការប្រាក់តាមផ្លូវច្បាប់។



Scanned with CamScanner

៣.បង្គាប់ឱ្យចុងចម្លើយ សងសំណងជំងឺចិត្ត និងការខាតបង់ពេលវេលា ចំនួន ១២,០០០,០០០៛ (ដប់ពីរលាន រៀល) ទៅឱ្យដើមចោទឈ្មោះ [redacted] គឺមមួយ ។

៤. សាលក្រមនេះមានអានុភាពអនុវត្តបណ្ដោះអាសន្ន ត្រង់ចំណុចទី១ នៃសេចក្ដីសម្រេច។

៥. ចុងចម្លើយ ជាអ្នករ៉ាប់រងប្រាក់ប្រដាប់ក្ដី ។

សាលក្រមនេះបញ្ចប់ការទាញហេតុផលផ្ទាល់មាត់ នៅថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០២០ ចំពោះមុខដើមចោទ និងអ្នកតំណាងដោយអាណត្តិឱ្យដើមចោទ កំបាំងមុខចុងចម្លើយ ប្រកាសជាសាធារណៈនៅថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០២០ ។

គូភាគីមានសិទ្ធិប្ដឹងទាស់ និងឧទ្ធរណ៍ ក្នុងរយៈពេលដែលច្បាប់បានកំណត់។

ចៅក្រម

ហត្ថលេខា និងត្រា: [redacted]

"បានចម្លងត្រឹមត្រូវតាមសាលក្រមដើម"

ថ្ងៃអង្គារ ១១ កើត ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

រាជធានីភ្នំពេញ, ថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០២០

ក្រឡាបញ្ជី

[redacted]

បានឃើញ

ចៅក្រម

[redacted]



Scanned with CamScanner